**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible]......សហវ.[illegible]

# ប្រកាស

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ដាការិយាល័យនៃសាខាគយនិងរដ្ឋាករនាំចេញ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ៣៨៩សហវ.ប្រកចុះថ្ងៃ១៧ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃសាខាគយនិងរដ្ឋាករនាំចេញ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់មុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ ។

**ប្រការ ២ .-**

ត្រូវបានបង្កើតនិងកំណត់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាខាគយ និងរដ្ឋាករនាំចេញ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនប្រាំ (៥) ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង

២. ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញរាជធានីភ្នំពេញ

៣. ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តកណ្តាល

៤. ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តកំពង់ស្ពឺ

៥. ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តនានា ។

**ប្រការ ៣ .-**

ការិយាល័យនីមួយៗរបស់សាខាគយ និងរដ្ឋាករនាំចេញនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការដែលទទួលខុសត្រូវតាមភារកិច្ច ដែលកំណត់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤ .-**

ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង ជាសេនាធិការឱ្យសាខាគយ និងរដ្ឋាករនាំចេញនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានមុខងារ និងភារកិច្ចដូចតទៅ÷

- ទទួលបន្ទុកការងារគ្រប់គ្រងរដ្ឋបាល ស្ថិតិ និងគណនេយ្យរបស់សាខាគយនិងរដ្ឋាករនាំចេញ
- ធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ និងបំពេញភារកិច្ចស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចពាក់ព័ន្ធតាមបទប្បញ្ញត្តិជាធរមាន
- ចូលរួមកសាង និងអនុវត្តគោលនយោបាយ ព្រមទាំងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការនាំចេញឈានទៅជំរុញប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មតាមការអនុវត្តល្អជាអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៥ .-**

ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញរាជធានីភ្នំពេញ, ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តកណ្តាល និងការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តកំពង់ស្ពឺ ជាសេនាធិការឱ្យសាខាគយនិងរដ្ឋាករនាំចេញ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានមុខងារនិងភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធនិងអាករលើទំនិញនាំចេញគ្រប់ប្រភេទតាមមណ្ឌលសន្និធិគយបណ្តោះអាសន្ន និង តាមអាជីវកម្មដ្ឋាននានារបស់វិនិយោគិនដែលស្ថិតក្រោមរូបភាពវិនិយោគក្នុងភូមិសាស្ត្រគ្រប់គ្រងនិងដែនសមត្ថកិច្ចពាក់ព័ន្ធរបស់ខ្លួន

- បំពេញភារកិច្ចស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ខ្លួនតាមបទប្បញ្ញត្តិជាធរមាន ដោយសហការជាមួយអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចនានា
- ចូលរួមកសាង និងអនុវត្តគោលនយោបាយ ព្រមទាំងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការនាំចេញឈានទៅជំរុញប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មតាមការអនុវត្តល្អជាអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៦ . -**

ការិយាល័យត្រួតពិនិត្យគយលើទំនិញនាំចេញខេត្តនានា ជាសេនាធិការឱ្យសាខាគយនិងរដ្ឋាករនាំចេញនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានមុខងារនិងភារកិច្ចដូចតទៅ÷

- គ្រប់គ្រងត្រួតពិនិត្យ និងប្រមូលពន្ធនិងអាករលើទំនិញនាំចេញគ្រប់ប្រភេទតាមសន្និធិគយបណ្តោះអាសន្ននិងតាមអាជីវកម្មដ្ឋាននានារបស់វិនិយោគិនដែលស្ថិតក្រោមរូបភាពវិនិយោគតាមបណ្តាខេត្តនានាក្រៅពីភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ
- បំពេញភារកិច្ចស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ខ្លួនតាមបទប្បញ្ញត្តិជាធរមាន ដោយសហការជាមួយអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចនានា
- ចូលរួមកសាង និងអនុវត្តគោលនយោបាយ ព្រមទាំងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការនាំចេញឈានទៅជំរុញប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មតាមការអនុវត្តល្អជាអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៧ . -**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨ . -**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ